# តើអ្នកមានវិក្កយបត្រថ្លៃថែទាំសុខភាព ដែលអ្នកមិនមានលទ្ធភាពបង់ដែរឬទេ? ជំនួយមានផ្តល់ជូន។

ព័ត៌មានអំពីគោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ Partners HealthCare មានផ្តល់ជូនជាភាសាផ្សេងៗ។ សូមចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំ ទូរស័ព្ទមកយើងខ្ញុំ ឬទៅជួបអ្នកប្រឹក្សាហិរញ្ញវត្ថុសម្រាប់អ្នកជំងឺ នៅមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលថែទាំសុខភាពរបស់អ្នក ដើម្បីទទួលបានព័ត៌មានដែលបានបកប្រែ។

## កម្មវិធីរបស់រដ្ឋ

ប្រសិនបើអ្នករស់នៅក្នុងរដ្ឋ Massachusetts អ្នកអាចនឹងទទួលបានការធានារ៉ាប់រងសុខភាព ឬជំនួយក្នុងការទូទាត់វិក្កយបត្រថ្លៃថែទាំសុខភាពរបស់អ្នក តាមរយៈកម្មវិធីរបស់រដ្ឋ ដូចជា MassHealth, Health Connector ឬ Health Safety Net។ កម្មវិធីនីមួយៗមានវិធានផ្សេងៗគ្នា និងកម្រិតកំណត់លើប្រាក់ចំណូលខុសៗគ្នា។

ដើម្បីស្វែងយល់បន្ថែម និងដាក់ពាក្យសុំ៖

- ទៅជួបអ្នកប្រឹក្សាហិរញ្ញវត្ថុសម្រាប់អ្នកជំងឺ នៅមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលថែទាំសុខភាពរបស់អ្នក ឬ
- ចូលទៅកាន់គេហទំព័រ www.MAhealthconnector.org

## ការចុះតម្លៃ

ប្រសិនបើអ្នកទទួលបានវិក្កយបត្រថ្លៃពេទ្យ ដោយសារតែអ្នកមិនមានការធានារ៉ាប់រង ឬ ដោយសារតែការធានារ៉ាប់រងសុខភាពរបស់អ្នក មិនបានរ៉ាប់រងការថែទាំសុខភាពរបស់អ្នកនោះ អ្នកអាចនឹងមានគ្រប់លក្ខណៈសម្បត្តិទទួលការបញ្ចុះតម្លៃ។ ពាក្យសុំ និងឯកសារជំនួយ អាចនឹងតម្រូវឲ្យមាន។ ការបញ្ចុះតម្លៃមាន 3 ប្រភេទ៖

1. ប្រសិនបើវិក្កយបត្ររបស់អ្នក គឺសម្រាប់ថ្លៃសង្គ្រោះបន្ទាន់ និងទាក់ទងនឹងការថែទាំវេជ្ជសាស្ត្រដែលត្រូវតាមដាន អ្នកអាចទទួលបានការបញ្ចុះតម្លៃពី 70% ទៅ 100% ប្រសិនបើអ្នកមិនមានគ្រប់លក្ខណៈសម្បត្តិសម្រាប់កម្មវិធីណាមួយរបស់រដ្ឋទេនោះ។ ចំនួននៃការបញ្ចុះតម្លៃ នឹងអាស្រ័យលើប្រាក់ចំណូលនៃក្រុមគ្រួសាររបស់អ្នក។*
2. ប្រសិនបើវិក្កយបត្ររបស់អ្នកចេញដោយ Spaulding ឬ McLean នោះអ្នកអាចនឹងទទួលបានការបញ្ចុះតម្លៃពី 55% ទៅ 100% ប្រសិនបើអ្នកមិនមានគ្រប់លក្ខណៈសម្បត្តិសម្រាប់កម្មវិធីណាមួយរបស់រដ្ឋទេនោះ។ ទំហំនៃការបញ្ចុះតម្លៃនឹងអាស្រ័យលើប្រាក់ចំណូលនៃក្រុមគ្រួសាររបស់អ្នក។*
3. អ្នកអាចនឹងទទួលបានការបញ្ចុះតម្លៃ 25% ចំពោះវិក្កយបត្រថ្លៃពេទ្យនានា ប្រសិនបើអ្នកបង់ប្រាក់ (ឬរៀបចំគម្រោងបង់ប្រាក់) ក្នុងរយៈពេល 2 ខែ បន្ទាប់ពីកាលបរិច្ឆេទនៅលើវិក្កយបត្រដំបូងរបស់អ្នក។

**សំខាន់៖** វិក្កយបត្រថ្លៃថែទាំសុខភាពជាច្រើន គឺសម្រាប់សហការទូទាត់ សហធានារ៉ាប់រង ឬចំណែកត្រូវបង់ដោយអ្នកត្រូវបានធានារ៉ាប់រង ដែលត្រូវបានតម្រូវជាផ្នែកមួយនៃធានារ៉ាប់រងសុខភាពរបស់អ្នក។ យើងខ្ញុំមិនបញ្ចុះតម្លៃចំពោះវិក្កយបត្រទាំងនោះទេ។

## គម្រោងបង់ប្រាក់

អ្នកអាចរៀបចំគម្រោងបង់ប្រាក់ប្រចាំខែដោយគ្មានការប្រាក់ ចំពោះវិក្កយបត្រណាមួយ ទោះបីជាវិក្កយបត្រសម្រាប់សហការទូទាត់ សហធានារ៉ាប់រង ឬចំណែកត្រូវបង់ដោយអ្នកត្រូវបានធានារ៉ាប់រងសុខភាព។ សូមទូរស័ព្ទមកយើងខ្ញុំដើម្បីរៀបចំគម្រោងបង់ប្រាក់។

**សូមទាក់ទងមកយើងខ្ញុំដើម្បីស្វែងយល់បន្ថែម។ ទម្រង់ពាក្យសុំ និងជំនួយ មានផ្តល់ជូនដោយឥតគិតថ្លៃ។**

1) ទំនាក់ទំនងដោយផ្ទាល់៖ មកជួបអ្នកប្រឹក្សាហិរញ្ញវត្ថុសម្រាប់ចំពោះអ្នកជំងឺ នៅមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលសុខភាពរបស់អ្នក
2) ទូរស័ព្ទ៖ (617) 726-3884
3) គេហទំព័រ៖ www.partners.org/financialassistance
4) អ៊ីម៉ែល៖ patientbilling@partners.org
5) សំបុ      សូម ទូរស័ព្ទ ឬអ៊ីម៉ែល ដើម្បីស្នើសុំព័ត៌មាន និងទ   ង់ពាក្យសុំតា មរយៈអ៊ីម៉ែល។

សូមដាក់ពាក្យស្នើសុំឥឡូវនេះ។ រយៈពេលអាចនឹងកំណត់ដើម្បីដាក់ពាក្យសុំ។

* អ្នកនឹងមិនបង់ប្រាក់ច្រើនជាងអ្វីដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ជាមធ្យមនោះទេ។ អត្រាបញ្ចុះតម្លៃនឹងត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយអាចនឹងផ្លាស់ប្តូរ។ សូមពិនិត្យមើលនៅលើគេហទំព័ររបស់យើងខ្ញុំ សម្រាប់អត្រាបច្ចុប្បន្ន។

| | | |
|---|---|---|
| **Brigham and Women's Hospital**<br>45 Francis Street<br>ASB II – 2nd floor<br>(617) 732-7005<br>(866) 736-1510 | **Brigham and Women's Hospital Ambulatory Care Center**<br>850 Boylston Street<br>Suite 204B<br>(617) 732-9677 | **Brookside Community Health Center**<br>3297 Washington Street<br>Jamaica Plain, MA 02130<br>(617) 983-6054 |
| **Southern Jamaica Plain Health Center**<br>640 Centre Street<br>Jamaica Plain, MA 02130<br>(617) 983-4100 | **Brigham and Women's/Mass General Health Care Center**<br>20 Patriot Place, 20PP1<br>Foxborough, MA 02035<br>(508) 718-4196 | **Brigham and Women's Faulkner Hospital**<br>1153 Centre Street, Suite 1106<br>Boston, MA 02130<br>(617) 983-7878 |
| **Cooley Dickinson Hospital**<br>30 Locust Street<br>Northampton, MA 01061<br>(413) 582-2021 | **Martha's Vineyard Hospital**<br>One Hospital Road<br>Oak Bluffs, MA 02557<br>(508) 957-0157 | **Massachusetts General Hospital (MGH)**<br>Main Campus<br>Wang Ambulatory Center<br>WACC-1, Room 150<br>(617) 726-2191 |
| **MGH Yawkey Outpatient Care Center**<br>Second Floor – Room 2A<br>(617) 726-2191 | **MGH Charlestown HealthCare Center**<br>73 High Street<br>Charlestown, MA 02129<br>(617) 724-8166<br>(617) 724-8167 | **MGH Chelsea HealthCare Center**<br>151 Everett Avenue<br>Chelsea, MA 02150<br>(617) 884-8300 |
| **MGH Revere HealthCare Center**<br>300 Ocean Avenue<br>Revere, MA 02151<br>(781) 485-6394<br>(781) 485-6090 | **Mass General/North Shore Center for Outpatient Care**<br>102 Endicott Street<br>Office: 1039<br>Danvers, MA<br>(617) 726-2191 | **Nantucket Cottage Hospital**<br>57 Prospect St<br>Nantucket, MA 02554<br>(508) 825-8387<br>(508) 825-8256 |
| **Newton-Wellesley Hospital**<br>2014 Washington Street<br>Newton, MA 02462<br>(617) 243-6824 | **North Shore Medical Center Salem Hospital Campus**<br>81 Highland Ave**nue**<br>Salem, MA 01970<br>(978) 825-6900 | **North Shore Medical Center Union Hospital Campus**<br>500 Lynnfield Street<br>Lynn, MA 01904<br>(781) 477-3555 |
| **Spaulding Rehabilitation Hospital Boston**<br>300 First Avenue, CNY<br>Charlestown, MA 02129<br>(617) 952-5337 | **Spaulding Hospital for Continuing Medical Care Cambridge**<br>1575 Cambridge Street<br>Cambridge, MA 02138<br>(617) 758-5338 | **Spaulding Rehabilitation Hospital Cape Cod**<br>311 Service Road<br>East Sandwich, MA 02537<br>(508) 833-4285<br>(508) 833-4246 |

Updated 7/2016